**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ០៣៤៤ ស ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣

# សេចក្តីណែនាំ

## ស្តីពីការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

យោងតាមប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

**១. ការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**ក. ការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត មានសមាសភាពដូចបានកំណត់នៅក្នុងប្រការ៦នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តដោយមានការឯកភាពក្នុងគណៈអភិបាលរបស់ខ្លួន ត្រូវសម្រេចជ្រើសរើសអភិបាលរង០១រូប ជាបេក្ខជនអនុប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន។

ក្រុមប្រឹក្សារាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីសម្រេចជ្រើសរើសសមាជិកក្រុមប្រឹក្សារាជធានី ខេត្តយ៉ាងច្រើន០៣រូប ដែលក្នុងនោះត្រូវមានស្ត្រីជាបេក្ខជនសមាជិកនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត។ ប្រធានក្រុមប្រឹក្សារាជធានី ខេត្តត្រូវបញ្ជូនឈ្មោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្តដែលបានជ្រើសរើសទាំងនោះជាលាយលក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្តដើម្បីបញ្ចូលទៅក្នុងសំណើសមាសភាពគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត។

នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សា ជាបេក្ខជនសមាជិកគណៈកម្មាធិការលទ្ធកម្ម និងកំណត់បានពីសមាសភាពអភិបាលរង០១រូបជាបេក្ខជនអនុប្រធានគណៈកម្មាធិការលទ្ធកម្ម អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ដោយរួមបញ្ចូលនូវសមាសភាពដទៃទៀតដូចបានកំណត់នៅក្នុងប្រការ៦នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័ត។ ✓

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh